Australian Government

Aged Care Quality and Safety Commission

Aged care **reforms**

# ក្រមសីលធម៌សម្រាប់ការថែទាំមនុស្សចាស់

ក្រមសីលធម៌សម្រាប់ការថែទាំមនុស្សចាស់ ពិពណ៌នាអំពីរបៀបដែលអ្នកត្រូវប្រកាន់អាកប្បកិរិយា និងប្រព្រឹត្តចំពោះអ្នកប្រើប្រាស់។ វារួមបញ្ចូលចំណុចសំខាន់ៗ 8 ខាងក្រោម។

**A.** ប្រព្រឹត្តដោយមានការគោរពចំពោះសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់មនុស្ស ការសម្រេចចិត្តដោយខ្លួនឯង និងការធ្វើសេចក្តីសម្រេចចិត្តស្របតាមច្បាប់ និងអនុសញ្ញានានាដែលអាចអនុវត្តបាន។

**B.** ប្រព្រឹត្តតាមរបៀបដែលចាត់ទុកមនុស្សទាំងឡាយប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរព ហើយឱ្យតម្លៃលើភាពចម្រុះរបស់ពួកគេ។

**C.** ប្រព្រឹត្តដោយមានការគោរពឯកជនភាពរបស់មនុស្សទាំងឡាយ។

**D.** ផ្តល់ការថែទាំ ការគាំទ្រ និងសេវាកម្មតាមលក្ខណៈមួយដែលមានសុវត្ថិភាព និងសមត្ថភាព ដោយមានការយកចិត្តទុកដាក់ និងបំណិន

**E.** ធ្វើសកម្មភាពដោយសុចរិតភាព ភាពស្មោះត្រង់ និងតម្លាភាព។

**F.** ចាត់វិធានការភ្លាមៗដើម្បីលើកឡើង និងធ្វើសកម្មភាពលើការព្រួយបារម្ភអំពីបញ្ហានានាដែលអាចប៉ះពាល់ដល់គុណភាព និងសុវត្ថិភាពនៃការថែទាំ ការគាំទ្រ និងសេវាកម្ម។

**G.** ផ្តល់ការថែទាំ ការគាំទ្រ និងសេវាកម្មរួចផុតពី៖

i. គ្រប់ទម្រង់នៃអំពើហិង្សា ការរើសអើង ការកេងប្រវ័ញ្ច ការធ្វេសប្រហែស និងការរំលោភបំពាន ហើយនិង

ii. ការប្រព្រឹត្តមិនត្រឹមត្រូវលើផ្លូវភេទ។

**H.** ចាត់វិធានការសមស្របទាំងអស់ដើម្បីបង្ការ និងឆ្លើយតបចំពោះ៖

i. គ្រប់ទម្រង់នៃអំពើហិង្សា ការរើសអើង ការកេងប្រវ័ញ្ច ការធ្វេសប្រហែស និងការរំលោភបំពាន ហើយនិង

ii. ការប្រព្រឹត្តមិនត្រឹមត្រូវលើផ្លូវភេទ។

ស្វែងយល់បន្ថែមទៀត:

**គណៈកម្មការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពថែទាំមនុស្សចាស់**

agedcarequality.gov.au/providers/code-conduct-aged-care-information-workers

ខែធ្នូ ឆ្នាំ 2022

ACR-COC-021

Aged care **reforms**